# ការស្លាប់ក្នុងពេលតវ៉ានៅប្រទេសកម្ពុជាៈ អ្នកជំនាញការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិជំរុញឲ្យគ្រប់ភាគីទាំងអស់ ស្ងៀមស្ងាត់ និង អត់ធ្មត់

ហ្សឺណែវ (ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០១៤) អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា សុរិយា ស៊ូប៊ែឌី បានបញ្ជាក់ពីការអំពាវនាវរបស់គាត់ឲ្យមានការស្ងៀមស្ងាត់ បន្ទាប់ពីកម្លាំងកងរាជអាវុធហត្ថបានបាញ់ទៅលើកម្មករកាត់ដេរធ្វើកូដកម្ម ដោយយ៉ាងហោចណាស់មនុស្សបួននាក់ ត្រូវបានបាញ់សម្លាប់។

នេះគឺជាលើកទីបីហើយចាប់តាំងពីការបោះឆ្នោតជាសកលនៅខែកក្កដា ឆ្នាំ ២០១៣ ដែលមានវិវាទ ដែលអាជ្ញាធរបានបាញ់ទីលើហ្វូងមនុស្ស និង បណ្តាលឲ្យស្លាប់ជាច្រើននាក់។

លោក ស៊ូប៊ែឌី បានមានប្រសាសន៍ថា "ខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំងពីការប៉ះទង្គិចនាពេលថ្មីៗនេះនៅក្នុងប្រទេសកម្ពុជា ហើយមានការអាណិតអាសូរលើការបាត់បង់ជីវិតរបស់មនុស្ស។ ខ្ញុំសូមអំពាវនាវឲ្យអាជ្ញាធរធ្វើការអត់ធ្មត់ចំពោះអ្នកតវ៉ា។ ការប្រើកម្លាំងណាពីក្រុមមន្ត្រី ត្រូវធ្វើឡើងតាមគោលការណ៍ត្រឹមត្រូវតាមច្បាប់ ស្ថាភាពចាំបាច់ និង សមាមាត្រ"។

គាត់បានបន្ថែមថា "ត្រូវតែមានការស៊ើបអង្កេតឯករាជ្យជាបន្ទាន់ ថាតើមានការប្រើប្រាស់កម្លាំងជ្រុលពេកក្នុងលើកនេះ និង ពីរលើកមុនដែរឬទេ"។

លោក ស៊ូប៊ែឌី ក៏បានសំដែងការព្រួយបារម្ភផងដែរថា បាតុករមួយចំនួនមានការកើនឡើងនៃការងាកទៅរកអំពើហិង្សា ហើយបានគប់ដុំថ្ម និង បំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។

អ្នកជំនាញការឯករាជ្យបាននិយាយថា "ខ្ញុំសូមអំពាវនាវឲ្យអ្នកតវ៉ាទាំងអស់ ដោយមិនគិតពីហេតុផលតវ៉ារបស់គេយ៉ាងណានោះទេ ត្រូវធ្វើការអត់ធ្មត់ជាអតិបរមា"។

ជាថ្មីម្តងទៀត អ្នករាយការណ៍ពិសេសបានអំពាវនាវឲ្យមានការចចារដ៏មានសារៈសំខាន់អំពីការទាមទាររបស់កម្មករកាត់ដេរ ដែលបានចាប់ផ្តើមតវ៉ាជាច្រើនសប្តាហ៍មកនេះ ដើម្បីសុំតម្លើងប្រាក់ឈ្នួលអប្បបរិមា។

ការធ្វើកូដកម្មរបស់កម្មករកាត់ដេរ បានបន្ថែមសាំងទៅនឹងបាតុកម្មផ្នែកនយោបាយ ដែលរៀបចំឡើងចាប់តាំងពីខែកក្កដា ដោយគណបក្សប្រឆាំង ដើម្បីទាមទារឲ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះចេញពីតំណែង និង ការបោះឆ្នោតឡើងវិញ។

លោក ស៊ូបេឌី បានមានប្រសាសន៍ថា “គេឃើញថា បច្ចុប្បន្ននេះ ប្រទេសកម្ពុជាកំពុងកើតមានឡើងបាតុកម្មជារៀងរាល់ថ្ងៃ។ វាជាការស្វាគមន៍ដែលថា បច្ចុប្បន្ននេះ ប្រជាជនកម្ពុជាមានអារម្មណ៍ថា ពួកគេអាចអនុវត្តសិទ្ធិតវ៉ារបស់គេ ប៉ុន្តែការតវ៉ាត្រូវតែធ្វើឡើងដោយសន្តិវិធី”។

**(*)** សូមមើលរបាយការណ៍ចុងក្រោយរបស់អ្នករាយការណ៍ពិសេស ដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស (A/HRC/24/36): http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session24/Pages/ListReports.aspx ។